**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ ១០១៥ សហវ.ប្រក.

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០០៦

# ប្រកាស
## ស្តីពី
## ការបង្កើតក្រុមសម្របសម្រួលអន្តរស្ថាប័ន នៃកិច្ចសម្រួលពាណិជ្ជកម្ម តាមរយៈការគ្រប់គ្រងហានិភ័យ

*** ៚ ***

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
## និងជាប្រធានគណៈកម្មាធិការដឹកនាំការងារដើម្បីអភិវឌ្ឍន៍ផ្នែកឯកជន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញសេចក្តីសំរេចរបស់រាជរដ្ឋាភិបាលលេខ ៤៤ សសរ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការបង្កើតគណៈកម្មាធិការដឹកនាំការងារដើម្បីអភិវឌ្ឍន៍ផ្នែកឯកជន
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ បក ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០០៦ ស្តីពីកិច្ចសម្រួលពាណិជ្ជកម្មតាមរយៈការគ្រប់គ្រងហានិភ័យ
- យោងសេចក្តីជូនដំណឹងរបស់រាជរដ្ឋាភិបាល លេខ ៩០ សជណ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០០៥
- យោងលិខិតលេខ ១៨៩០ MOC/SM 2006 ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០០៦ របស់ក្រសួងពាណិជ្ជកម្ម
- យោងលិខិតលេខ ០៩០៥ អបស/ឱអបស ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០០៦ របស់ក្រសួងសុខាភិបាល
- យោងលិខិតលេខ ៥៣០១ កសក ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ២០០៦ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- យោងលិខិតលេខ ១៥៨៧ ឧរថ.អឱ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៦ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- យោងលិខិតលេខ ២៩៩០/០៦ គ.ស.ព ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០០៦ របស់គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា
- តាមតម្រូវការចាំបាច់នៃការងារ

## សំរេច

**ប្រការ ១:** បង្កើតក្រុមសម្របសម្រួលអន្តរស្ថាប័ន នៃកិច្ចសម្រួលពាណិជ្ជកម្ម តាមរយៈការគ្រប់គ្រងហានិភ័យ ដើម្បីបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងប្រតិបត្តិការនៃការនាំចេញ នាំចូលទំនិញ តាមរយៈការអនុវត្តន៍ការគ្រប់គ្រងហានិភ័យ ហៅកាត់ថា "ក្រុមសម្របសម្រួលអន្តរស្ថាប័ន"។

**ប្រការ ២:** ក្រុមសម្របសម្រួលអន្តរស្ថាប័ននេះដឹកនាំដោយ **ឯកឧត្តម ម៉ែន ស៊ីម៉ន** ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជានាយកទីចាត់ការគយនិងរដ្ឋាករ និងមានសមាជិកចូលរួមដូចខាងក្រោម :

| | |
|---|---|
| ១- បណ្ឌិត **គុណ ញឹម** | នាយករង ទីចាត់ការគយនិងរដ្ឋាករ |
| ២- ឯកឧត្តម **ម៉ក់ ពេជ្ររិទ្ធ** | ប្រធាននាយកដ្ឋានកាំកុងត្រូល នៃក្រសួងពាណិជ្ជកម្ម |
| ៣- ឯកឧត្តម **ម៉ែន សំអាន** | ប្រធានការិយាល័យលេខាធិការនិងជំនួយការ នៃទីចាត់ការគយនិងរដ្ឋាករ |
| ៤- លោក **មាន សុភា** | ប្រធាននាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម |
| ៥- លោក **សាត សមុទ្រ** | អគ្គនាយករងឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល |
| ៦- លោក **នួន ចំន្ទរិទ្ធ** | ប្រធានការិយាល័យបច្ចេកទេសគយ និងជាប្រធានការិយាល័យកិច្ចការអន្តរជាតិ នៃទីចាត់ការគយនិងរដ្ឋាករ |
| ៧- លោក **ទឹម យឹមហ៊ាង** | អនុប្រធាននាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារ ពេទ្យ និងគ្រឿងសំអាង ទទួលបន្ទុកផ្នែកអាជីវកម្ម ឱសថ នៃក្រសួងសុខាភិបាល |
| ៨- លោក **ហ៊ាន វណ្ណហាន** | អនុប្រធាននាយកដ្ឋានក្សេត្រសាស្ត្រ និងកែលំអដី កសិកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| ៩- លោក **សួន សុធឿន** | អនុប្រធាននាយកដ្ឋានផលិតកម្ម និងពសុពេទ្យបាល នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ |

១០- លោក **នាង ពុទ្ធារ៉ា** អនុប្រធានការិយាល័យប្រតិបត្តិការ និងគ្រប់គ្រង នៃ គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា

ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកទីចាត់ការគយនិងរដ្ឋាករ អាចចាត់តាំងសមាជិកណាម្នាក់នៃក្រុមសម្របសម្រួលស្ថាប័ន ដើម្បីដឹកនាំសម្របសម្រួលការងារក្រុមសម្របសម្រួលអន្តរស្ថាប័ននេះជាបណ្តោះអាសន្នក្នុងករណីចាំបាច់។

**ប្រការ ៣:** ក្រុមសម្របសម្រួលអន្តរស្ថាប័ននេះ មានភារកិច្ចដូចខាងក្រោម ÷

១- ធានាសម្រេចឱ្យបាននូវតុល្យភាពផ្អែកលើហានិភ័យប្រកបដោយប្រសិទ្ធភាព រវាងអន្តរាគមន៍ខាងបទប្បញ្ញត្តិ និងការសម្រួលពាណិជ្ជកម្មក្នុងចំណោមក្រសួង និងស្ថាប័នដែលពាក់ព័ន្ធនឹងការគ្រប់គ្រងប្រតិបត្តិការនៃការនាំចេញ នាំចូលទំនិញ។

២- កំណត់តួនាទី និងការទទួលខុសត្រូវទាំងឡាយរបស់ស្ថាប័ន ដើម្បីធានាឱ្យបានថា ស្ថាប័នទាំងឡាយរក្សាកិច្ចសហប្រតិបត្តិការគ្នាកម្រិតខ្ពស់ និងពុំមានសកម្មភាពត្រួតគ្នា។

៣- សម្របសម្រួលផែនការ និងសកម្មភាពជាយុទ្ធសាស្ត្រទាក់ទិននឹងការគ្រប់គ្រងប្រតិបត្តិការនៃការនាំចេញ នាំចូល ដែលរួមមានកិច្ចព្រមព្រៀងលើគោលដៅរួម។

៤- ពិនិត្យឡើងវិញនូវនីតិវិធីសម្រាប់ការបញ្ចេញទំនិញ និងត្រួតពិនិត្យទំនិញពាណិជ្ជកម្មអន្តរជាតិ និងតាមការចាំបាច់បង្កើតនូវនីតិវិធីដែលមានប្រសិទ្ធភាព សម្រាប់ការអនុវត្តន៍ ទន្ទឹមគ្នានឹងការដាក់ឱ្យអនុវត្តវិធីបញ្ចេញទំនិញតាមប្រព័ន្ធអេឡិកត្រូនិក។

៥- រៀបចំ និងតាមដានត្រួតពិនិត្យការអនុវត្តន៍សេចក្តីណែនាំរដ្ឋបាលសម្រាប់ការត្រួតពិនិត្យ និងការបញ្ចេញទំនិញនាំចូល និងនាំចេញ។

៦- ផ្សព្វផ្សាយអំពីតួនាទី និងការទទួលខុសត្រូវរបស់ស្ថាប័ន ដើម្បីផ្តល់ជូនសហគមន៍ពាណិជ្ជកម្មអន្តរជាតិ នូវការយល់ដឹងច្បាស់លាស់អំពីដំណើរការពាក់ព័ន្ធនឹងប្រតិបត្តិការនៃការនាំចេញ នាំចូល។

៧- ឃ្លាំមើលប្រសិទ្ធភាពនៃនីតិវិធីសម្រាប់ការបញ្ចេញ និងត្រួតពិនិត្យទំនិញពាណិជ្ជកម្មអន្តរជាតិ ដោយប្រើប្រាស់ការគ្រប់គ្រងហានិភ័យ និងផ្តួចផ្តើមសកម្មភាពកែតម្រូវតាមការចាំបាច់។

**ប្រការ ៤:** ក្រុមសម្របសម្រួលអន្តរស្ថាប័ន ត្រូវដំណើរការការងាររបស់ខ្លួនឱ្យបានស្របតាមខ្លឹមសារ នៃអនុក្រឹត្យ និងឧបសម្ព័ន្ធនៃអនុក្រឹត្យស្តីពីកិច្ចសម្រួលពាណិជ្ជកម្មតាមរយៈការគ្រប់គ្រងហានិភ័យដូចមានយោងខាងលើ និងមានសិទ្ធិប្រើប្រាស់ត្រារបស់ទីចាត់ការគយនិងរដ្ឋាករ។

**ប្រការ ៥:** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកទីចាត់ការគយនិងរដ្ឋាករ អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានពាក់ព័ន្ធនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អង្គភាព ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានរៀបរាប់ក្នុងប្រការ ២ ខាងលើ ត្រូវអនុវត្តតាមប្រកាសនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

គាត ឈន់

**ចម្លងជូន :**

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងសុខាភិបាល
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- ទីចាត់ការគយនិងរដ្ឋាករ
- គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា
- ដូចប្រការ៥ "ដើម្បីអនុវត្ត"
- ឯកសារ - កាលប្បវត្តិ